
សេរីការ

# ស្មារតី នៃ ថ្ងៃទី ១៧ មេសា

ស្មារតី នោះ វា ជា យថាប្រភេទ របស់ ពួក ខ្មែរកុម្មុយនិស្ត ដូច យ៉ាង នៅ សម័យ ខ្មែរក្រហម អង្គការលើ ក្នុងនាម បដិវត្តន៍ មហាលោតផ្លោះ បានសម្លាប់ ប្រជាជន ខ្លួនឯង ដល់នូវ គេ អាច អោយឈ្មោះបានជា ការសម្លាប់មហាជន។ អំពើ អហិរិក[1] នោះ បានប្រព្រឹត្ត ចាប់ពីថ្ងៃ ទី ១៧ មេសា ឆ្នាំ ១៩៧៥ ដែល ពួក ខ្មែរក្រហម គេទុកវា ជា ទីវា វិបុញ្ញ័យ នៃ កងទ័ពរំដោះជាតិ របស់បក្ស ដែលទទួលបាន វិជយៈយោធា[2] លើ ចក្រពត្រអាមេរីកាំង និង របប សាធារណរដ្ឋខ្មែរ។ មួយវិញទៀត ការថ្កើងចិត្ត[3] របស់ ពួកខ្មែរក្រហម នៅពេលនោះ គឺ ជ័យជំនះ យ៉ាងរហ័ស បំផុត របស់បក្សកុម្មុយនិស្តខ្មែរ ផ្ទាល់ខ្លួន ដែល ខ្លួន ទុកជា ជ័យជំនះ ញែកចេញ ពី យុទ្ធសាស្ត្រ បក្សកុម្មុយនិស្តយួន។ សេចក្តីប្រាថ្នា រក ឯករាជ្យ ចំពោះមុខ យួនកុម្មុយនិស្ត មានពិត នៅ ក្នុង ជម្រៅទឹកចិត្ត អ្នកដឹកនាំ បក្សកុម្មុយនិស្តខ្មែរ ព្រោះវា ជា ធម្មជាតិ របស់ ជនខ្មែរម្នាក់ៗ មាន ការដាស់តឿន ពី ប្រវត្តិសាស្ត្រជាតិ អំពី បាបមិត្ត[4] រវាង ខ្មែរ នឹង យួន; នុះ គំនិត អ្នកជាតិ

---

[1] អរិហិក; ignoble។

[2] វិជយៈយោធា ; grande victoire militaire។

[3] ការថ្កើងចិត្ត ; orgueil។

[4] បាបមិត្ត ; Mauvaise relation។

និយម តែងតែ មានប្រៀបលើជានិច្ច នៅក្នុង អារម្មណ៍ខ្មែរ។ គំនិត អ្នកជាតិនិយម នេះឯង វា ជា បដិសរីរ: ផង ជា កម្លាំងចិត្ត វៃតប ផង ចំពោះមុខ សត្រូវជាតិ។ បើនិយាយ ជា សង្ខេប គឺ វា ជា ព្រលឹងជាតិខ្មែរ[5] គឺថា វា ជា អង្គរក្ស សំរាប់ ការពារ ប្រជាជាតិ។

តែ គំនិត អ្នកជាតិនិយម របស់ ពួក អ្នកដឹកនាំ ខ្មែរក្រហម មាន ការបែងចែក ដាច់ស្រឡះពីគ្នា រវាង ជាតិ នឹង បុគ្គល។ ការបែងចែក បែបនេះ ជំរុញក្រៃពេក អោយ ពួកនោះ ឬ អង្គការលើ ទុក ជាតិ ជា បក្សកុម្មុយនិស្ត នូវ (ហើយនឹង) ទុក បុគ្គល ជា ឧបករណ៏ ដែល ជា ទស្សនៈ ផ្ទុយស្រឡះ ពី ទ្រឹស្តី លោក កាល ម៉ាក្ស (Karl Marx) ស្តីពី ឧបរិរចនាសម្ពន្ធ និង ហេដ្ឋារចនាសម្ព័ន្ធ ដែល វា មាន ការទំនាក់ទំនង នឹងគ្នា ជា បដិការ (ភាពមានទៅវិញទៅមក)។ ឧបករណ៏ វា អាច មាន ប្រយោជន៏ ឬ គ្មានប្រយោជន៏ សំរាប់ ប្រើ ក្នុង កិច្ចការ មួយ រីឯ ហេដ្ឋារចនាសម្ព័ន្ធ វិញ វា ជា ចំណែកមួយ ជៀសមិនរួច នៃ ឧបរិរចនាសម្ពន្ធ គឺថា វា ជា ចំណែកមួយ នៃ សារព័ន។ តាម អង្គការលើ បើ បុគ្គលណា មាន ប្រយោជន៏ ដល់បក្ស វាអាចទុក ជាមាន ប្រយោជន៏ ដល់ ជាតិ។ បុគ្គល មោឃ: ជា សត្រូវ នឹងជាតិ ព្រោះ វា ជា មាត់ សំរាប់ ហូប ឥតប្រយោជន៏ ដល់ជាតិ។ ដោយ បក្សកុម្មុយនិស្ត មាន ទិស បដិវត្តន៏ តែមួយ គឺ កសាង សង្គម

[5] ព្រលឹងជាតិខ្មែរ; fondement de la nation khmère។

កុម្មុយនិស្ត គ្មានដំណាក់ការ អន្តរការ ដូច្នេះ ត្រូវការ តែ បុគ្គល ឬ ឧបករណ៏ តែមួយ គឺ ជនកុម្មុយនិស្ត ជាសុក្រិត។ ដូច្នេះ បុគ្គលណា គ្មានប្រយោជន៏ ផ្ទាល់ ដល់បក្ស, អង្គការលើ ទុក ជា សត្រូវនឹងបក្ស ដែល អាច កំទិច ចោលបាន ដូចជា ឧបករណ៏ ឥតប្រយោជន៏ ទុកនាំតែវា រំខាន ដល់ ការដ្ឋាន នៃ បដិវត្តន៏។ ទស្សនៈ នៃ ប្រយោជន៍និយម នេះឯង ដែល វា កំទិច ព្រលឹង ជាតិ និង កម្លាំងប្រជាជន នាំអោយ ប្រជាជាតិ ខ្វះ អង្គការពារខ្លួន នៅក្នុង បរិស្ថាន នៅមាន ប្រទូសភាព ជាប្រវត្តិសាស្ត្រ រវាង សាមន្តប្រទេស[6]។ ក្នុងការស្វែងរកប្រយោជន៏ ដល់បក្ស នេះឯង ចំរុញអោយ អង្គការលើ ធ្វើ **បដិវត្តន៏ នៃ អង្គកាយ**[7] គឺ ថា វត្ថុ ជា សម្ភារៈក្ដី ជា វប្បធម៏ក្ដី ដែល បុគ្គល មាន នៅលើខ្លួន និង នៅក្នុងចិត្ត វា ជា ការបង្ហាញ នូវ ស្មារតី ជា ជម្រៅ របស់ បុគ្គល ប្រឆាំងនឹងបក្ស ដូចយ៉ាង បុគ្គល ពាក់ វ៉ែនតា, បុគ្គល ពាក់ ខោអាវ មាន ពណ៏ឆើតឆាយ, បុគ្គល ចេះនិយាយ ភាសាមស្ចិមប្រទេស ។ល។ ក៏ប៉ុន្តែ អង្គការ រចនា នូវ បច្ចេកទេស សម្ភារៈ[8] ជា អនញ្ញគំរូ (គំរូតែមួយ) សំរាប់អង្គកាយ នៃ បុគ្គល នៅក្នុង ស្មារតីរួម និង វិទ្យាសាស្ត្រ។ គំរូ ទោល នោះ វា ជា សារ នូវ ការសម្ដែង សេចក្ដីស្រឡាញ់ ដល់បក្ស ដូចយ៉ាង បុគ្គល ពាក់ ខោអាវ មាន ពណ៏ខ្មៅ, នារី កាត់សក់ខ្លី ។ល។ ព្រោះថា ទិដ្ឋភាព

---

[6] សាមន្តប្រទេស; ប្រទេសជិតខាង។

[7] បដិវត្តន៏ នៃ អង្គកាយ; révolution du corps។

[8] បច្ចេកទេស សម្ភារៈ; technique matérielle។

## ស្មារតី នៃ ថ្ងៃទី ១៧ មេសា

ក្រៅ ចុះនាមក្នុង បដិវត្តន៍ នៃ អង្គការ នៃ ជនកុម្មុយនិស្ត វា ជា សង្ខតធាតុ[9] មាន រូបភាព ជា ឧបករណ៍ សំរាប់ បំរើ បក្ស គឺ ថា នរជាតិ (être humain) ចំពោះបក្ស គឺ ជា វត្ថុ ជាសម្ភារ: តែ ប៉ុណ្ណោះ។ យើងអាច សន្និដ្ឋាន បានថា បដិវត្តន៍ នៃ អង្គការ វា ដូចជា ម៉ាស៊ិន នៃ ការបង្កើតផល ដើរ ក្នុង គោលដៅ ទោល រក ទិន្នផល ខ្ពស់ ជាដាច់ខាត។

**បដិវត្តន៍នយោបាយ** ដើរស្របគ្នានឹង បដិវត្តន៍ នៃ អង្គការ គឺ ការកំទិច នៃ វណ្ណ:សង្គម ដើម្បី កសាង សង្គមកុម្មុយនិស្ត បរិសុទ្ធ ដែល ត្រូវ រំលាយចោល តាមទស្សន:បក្ស នូវ អ្វី ជា អសុចិភាព (មិនសុទ្ធ)។ ទស្សន: នេះ គឺ ជា ការទុក នូវ អ្វី ដែល មិនបរិសុទ្ធ ជា សត្រូវ នឹងបក្ស ព្រោះ វា មាន ភាព ជា ការ ទទួលខុសត្រូវ ទាំងអស់ នៃ គុណវិបត្តិ មាន នៅក្នុង សង្គម មាន វណ្ណ: ឬ សង្គមចាស់។ សញ្ញាណ នៃ ពាក្យ ចាស់ សំរាប់ សង្គម កុម្មុយនិស្ត ឬ សង្គមថ្មី គឺជា អាភៀន នាំអោយខូច ចរិយាសង្គម បំពុល ប្រជាជន អោយ លិចខ្លួន ទៅក្នុង មនាចារ[10] រស់នៅ គ្មានប្រយោជន៍ ដល់ជាតិ។ ដូច្នេះ ទណ្ឌបត្តិ ដល់ ជន ជា មេក្រមី នៃ ជាតិ ជា ទោសនយោបាយ គឺ ទោសក្បត់ ជាតិ ត្រូវទទួលទោសប្រហារជីវិតភ្លាម។ បដិវត្តន៍នយោបាយ ត្រូវប្រើ មធ្យោបាយហិង្សា ចំពោះ ជន ណាមួយ ដែល មាន

---

[9] សង្ខតធាតុ ; matière vivante។

[10] មនាចារ; អបាយមុខ, ប្រព្រឹត្តហួសកំរិត; débauche។

ចរិយា មិន ជា ជនកុម្មុយនិស្ត គឺ ជា ជនបង្កើតផល និង ជនខ្ញុំបក្ស[11]។

បដិវត្តន៍នយោបាយ គឺ ឈរ លើ ទស្សនៈ ធំចម្បងពីរ ៖ ត្រួតត្រា និង ធ្វើទណ្ឌកម្ម ព្រោះ ការគោរពបក្ស ជា កាតព្វកិច្ច ដ្បិត អំណាចបក្ស ជា អំណាចបង្កើត ស្មារតីចេះដឹង ដើម្បី យកវាទៅអនុវត្ត អោយមានប្រយោជន៍ ដល់ជាតិ។ បក្ស សន្មត ថា ប្រជាជន នៅក្នុងសង្គមចាស់ គឺ ជា ឧក្រិដ្ឋជន ជា អ្នកទោសមនសិការ ដូច្នេះ ត្រូវមានគុក សំរាប់ ត្រួតត្រា និង ធ្វើទណ្ឌកម្ម តាម វិន័យ បដិវត្តន៍។ ការងាររួម ជា ការហត្ថកម្ម គឺ ត្រូវប្រព្រឹត្ត ក្នុង បរិច្ឆេទ តាមចង្វាក់មូល ដើម្បី អោយងាយស្រួលត្រួតពិនិត្យ នូវ វិរកម្ម (geste) នៃ ឧក្រិដ្ឋជនម្នាក់ៗ។ ការវិការនិមួយៗ នៃ បុគ្គលម្នាក់ៗ វា ជា វិញ្ញាសា ស្លាប់រស់ សំរាប់ខ្លួន នៅក្នុង ក្រមតែមួយ (codage) របស់អង្គការលើ។ ការស្វែងរក នៃ ការវិការ អវិរុទ្ធ ដើម្បី អោយមាន ប្រសិទ្ធិភាព អតិបរមា ជាគោលដៅលូង់ខ្លៅ របស់អង្គការលើ។

គោលដៅនេះឯងហើយ ដែលធ្វើអោយ ស្រុកខ្មែរ ក្លាយ ជា គុកឧក្រិដ្ឋ មាន ស្នាមភ្លោះ កប់ខ្មោច ប្រជាជន ពេញផ្ទៃដីនគរ នៅក្រោមអំណាច អង្គការលើ ដែល យក ការត្រួតត្រា របៀបតុលាការ[12] សំរាប់តែដាក់ទណ្ឌកម្មដល់ប្រហារជីវិត មកអនុវត្ត។

---

[11] ជនបង្កើតផល និង ជនខ្ញុំបក្ស ; individu productif et individu assujetti។

[12] របៀបតុលាការ; modèle judiciaire។

## ស្មារតី នៃ ថ្ងៃទី ១៧ មេសា

គ្រប់កំហុស គ្មានការបែងចែក កំរិត ព្រោះ ការទទួលទណ្ឌកម្ម វាមានតែមួយ គឺ ការប្រហារជីវិត។

ស្មារតី នៃ ថ្ងៃទី ១៧ មេសា វាជា និមិត្តរូប នៃ បដិវត្តន៍ អាជ្ញាព្រឹត្ត កំហក[13] របស់ គណបក្សកុម្មុយនិស្តខ្មែរ ដែលមានកម្មវិបាក រហូតមកដល់បច្ចុប្បន្នកាល ព្រោះ វាជា បដិវត្តន៍ ជាសេចក្តីល្ងង់ សំរាប់តែបំផ្លាញ នូវ ឧបរិចនាសម្ពន្ធ ឬ ព្រលឹងជាតិ នៃ សង្គមខ្មែរ និង ស្មារតី នៃ ការតស៊ូ មិនព្រមចាញ់ ចំពោះមុខ មហិច្ឆិតា ពាន់ឆ្នាំ របស់យួន។ បរាជ័យ ជា លជ្ជា[14] នៃ ថ្ងៃទី៧ មករា ឆ្នាំ ១៩៧៩ នៃ ពួកខ្មែរក្រហម ចំពោះមុខ កងទ័ពយួន ឈ្លានពាន បញ្ជាក់យ៉ាងច្បាស់លាស់ នូវ នយោបាយ តារខាក នៃ បដិវត្តន៍ ទុកខ្មែរ ជា សត្រូវនឹងបក្ស ហើយនឹងពន្លិច ប្រជាជាតិខ្មែរ ក្នុង ការប្រមាថ ពីសំណាក់ ជាតិសាសន៍យួន។ សព្វថ្ងៃនេះ យួន រើស កំទេច នៃ ពួកខ្មែរក្រហម មកប្រើឡើងវិញ ព្រោះ គេដឹងច្បាស់ ថា សុទ្ធ ជា ជនល្ងង់ខ្លៅ និងមនុស្សអសុត្យ សំរាប់ បំរើប្រយោជន៍យួន នៅក្នុង ទឹកដីខ្មែរដែល យួន ទុក ជា ទឹកដី របស់យួន។ យើងអាចសន្និដ្ឋានបានថា ស្មារតី នៃ ថ្ងៃទី ១៧ មេសា ជា ជ័យជំនះ ចុងក្រោយ របស់យួន នោះឯង។ ស្មារតី នៃ ថ្ងៃទី ១៧ មេសា និង ៧ មករា ជាស្មារតីតែមួយ គឺបំផ្លាញ និង រំលាយ ប្រជាជាតិខ្មែរ ដើម្បីយួន។

---

[13] បដិវត្តន៍ អាជ្ញាព្រឹត្ត កំហក, révolution autoritaire ratée។

[14] បរាជ័យ ជាលជ្ជា ឬ ដែលអោយអាម៉ាស់មុខ ; défaite honteuse។